**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ...០៥...បប

# បទបញ្ជា
## ស្តីពី
## វិធានការការពារ និង អភិរក្សដើមត្នោត

ដើមត្នោត គឺជាប្រភេទរុក្ខជាតិដែលមានសារប្រយោជន៍ពិសេសច្រើនយ៉ាង និង មានចំនួនច្រើនសន្ធឹកសន្ធាប់ ព្រមទាំងបានផ្សារភ្ជាប់ជាមួយប្រវត្តិសាស្ត្រ និង វប្បធម៌ដ៏យូរលង់នៃព្រះរាជាណាចក្រកម្ពុជាយើង។ ប្រជាជនខ្មែរទាំងអស់គ្នាមានមោទនភាព និង កិត្យានុភាពយ៉ាងក្រៃលែង ដោយសារបុព្វបុរសយើងជាច្រើនជំនាន់កន្លងមកបានខិតខំព្យាយាមដាំដុះ ថែរក្សា និង ការពារប្រភេទរុក្ខជាតិត្នោតរហូតបានបន្សល់ទុកជាកេរដំណែលនៅពាសពេញផ្ទៃប្រទេសដ៏មានតម្លៃខាងសេដ្ឋកិច្ច វប្បធម៌ ប្រវត្តិសាស្ត្រ និង បរិស្ថានឱ្យដល់ជំនាន់យើងបច្ចុប្បន្ននេះ។ អាស្រ័យហេតុនេះហើយ ទើបរាជរដ្ឋាភិបាលសម្រេចចាត់បញ្ចូលដើមត្នោតជាប្រភេទរុក្ខជាតិនិមិត្តរូបជាតិតាមរយៈព្រះរាជក្រឹត្យ លេខ.នស/រកត/០៣០៥/១៤៩ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០៥ ស្តីពីការកំណត់ ប្រភេទសត្វ និង រុក្ខជាតិសម្រាប់និមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងរក្សាទុកកេរដំណែលនៃមរតកធម្មជាតិនេះឱ្យបានគង់វង្សជានិរន្តរ៍។

កន្លងមករាជរដ្ឋាភិបាល ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាស្ថាប័នមានសមត្ថកិច្ចបានយកចិត្តទុកដាក់ខ្ពស់ក្នុងការការពារ និង ទប់ស្កាត់ការធ្វើអាជីវកម្មដើមត្នោតដោយអនាធិបតេយ្យដោយបានដាក់ចេញនូវវិធានការនានាក៏ដូចជាសារាចរណែនាំស្តីពីវិធានការទប់ស្កាត់ការដឹកជញ្ជូន និង ការធ្វើ អាជីវកម្ម ការកែច្នៃ ដើមត្នោតក្នុងគោលបំណងការពារ ថែរក្សា និង អភិរក្សដើមត្នោត ដែលជាប្រភេទរុក្ខជាតិនិមិត្តរូបជាតិនេះ។ ទោះជាមានវិធានការអនុវត្តហើយក្តី រាជរដ្ឋាភិបាលនៅតែសង្កេតឃើញមានសកម្មភាពនៃការកាប់រំលំដើមត្នោតជាលក្ខណៈប្រមូលផ្តុំសម្រាប់ធ្វើពាណិជ្ជកម្ម ដោយសារតែមានឈ្មួញកណ្តាលជាអ្នកបំផុសឱ្យកាប់ និង ដើរប្រមូលទិញ ធ្វើអាជីវកម្មដឹកជញ្ជូន កែច្នៃ នាំចេញទៅក្រៅប្រទេស ដែលធ្វើឱ្យសកម្មភាពកាន់តែកើនឡើងៗពីតំបន់មួយទៅតំបន់មួយទៀតជាបន្តបន្ទាប់ និង បង្កនូវវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់រុក្ខជាតិប្រភេទនេះ។ ម្យ៉ាងវិញទៀត ប្រជាកសិករខ្លះយល់ឃើញថាដើមត្នោតបានដុះក្នុងបរិវេណដីកម្មសិទ្ធិ

របស់គាត់ គាត់មានសិទ្ធិប្រើប្រាស់ និង លក់ដូរទៅតាមតម្រូវការ ដោយមិនបានពិចារណាថា ដើមត្នោតជារុក្ខជាតិដែលផ្តល់អត្ថប្រយោជន៍ច្រើនយ៉ាង យូរអង្វែង សម្រាប់ជីវភាពរស់នៅរបស់គាត់ ជារុក្ខជាតិតំណាងឱ្យនិមិត្តរូបជាតិ និង តំណាងឱ្យវប្បធម៌ខ្មែរដូចដែលមានចម្លាក់នៅលើជញ្ជាំងអង្គរវត្តជាសក្ខីភាពស្រាប់ និង មិនដែលនឹកស្មានថា កេរមរតកធម្មជាតិនេះ អាចឈានទៅរកការផុតពូជពីទឹកដីយើង ក៏ដូចជាធ្វើឱ្យបាត់បង់អត្តសញ្ញាណវប្បធម៌ អរិយធម៌ និង ប្រវត្តិសាស្ត្រធម្មជាតិរបស់ជាតិឡើយ។

ស្ថិតនៅក្នុងស្ថានភាពចំពោះមុខនេះ ដើម្បីធានាបាននូវការគ្រប់គ្រង និង ការប្រើប្រាស់ដើមត្នោតប្រកបដោយនិរន្តរភាព ទោះជាក្នុងរូបភាពឯកជន គ្រួសារ សហគមន៍ ឬ សាធារណៈក្តី និង ដើម្បីរក្សាបាននូវផលប្រយោជន៍សង្គម សេដ្ឋកិច្ច បរិស្ថាន និង វប្បធម៌របស់ប្រទេសជាតិ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវបទបញ្ជាដូចខាងក្រោម ៖

១-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីគ្រប់គ្រងសកម្មភាពទូទៅ ក្នុងការការពារ អភិរក្ស ដាំដុះ ប្រើប្រាស់ដើមត្នោតឱ្យមាននិរន្តរភាព។

២-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវបន្តផ្សព្វផ្សាយពីសារៈប្រយោជន៍របស់ដើមត្នោត និង ផលវិបាកនៃការបាត់បង់ដើមត្នោតជូនប្រជាពលរដ្ឋឱ្យបានយល់ជ្រួតជ្រាប។ លើសពីនេះទៅទៀត ត្រូវបន្តណែនាំឱ្យប្រជាពលរដ្ឋបានយល់ដឹង និង ចេះប្រើប្រាស់ដើមត្នោតឱ្យអស់លទ្ធភាព និង គប្បីកាប់តែដើមត្នោតណាដែលលែងផ្តល់ផល។

៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវបំផុសចលនាផល់ប្រជាពលរដ្ឋឱ្យចូលរួមដាំដើមត្នោតនៅក្នុងមូលដ្ឋាន ជាពិសេសនៅរាល់ពិធីរុក្ខទិវា "៩ កក្កដា" ដើម្បីជំនួសដើមត្នោតដែលកាប់យកមកប្រើប្រាស់ផង និង ធានាបាននូវនិរន្តរភាពដើមត្នោតឱ្យនៅរាយប៉ាយពាសពេញផ្ទៃប្រទេសកម្ពុជាយើងផង។ បណ្តាខេត្តដែលគ្មានព្រៃឈើ និង តំបន់ជាប់ព្រំដែនត្រូវជំរុញចលនាដាំដើមត្នោត ដើម្បីរក្សាអនាគតមរតកធម្មជាតិនេះឱ្យបានគង់វង្ស។

៤-អាជ្ញាធរមូលដ្ឋាន ត្រូវសហការជាមួយសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងការចុះស្រង់ស្ថិតិដើមត្នោតរបស់ប្រជាកសិករនៅគ្រប់មូលដ្ឋាន។

៥-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និង អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវសហការជាមួយសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចាត់វិធានការទប់ស្កាត់ជាបន្ទាន់ រាល់សកម្មភាពកាប់រំលំជាលក្ខណៈប្រមូលផ្តុំ ដែលនាំមកនូវវិនាសកម្មដល់ដើមត្នោត។

៦-ប្រជាពលរដ្ឋគ្រប់រូបត្រូវចូលរួមថែរក្សាការពារ អភិរក្ស និង ត្រូវចូលរួមដាំដើមត្នោតនៅលើដីកម្មសិទ្ធិរបស់ខ្លួន។

៧-កម្មសិទ្ធិករដើមត្នោត ត្រូវបានរក្សាសិទ្ធិក្នុងការប្រើប្រាស់ដើមត្នោត និង ផលិតផលពីដើមត្នោតរបស់ខ្លួនប្រកបដោយនិរន្តរភាព។

៨-ត្រូវបានអនុញ្ញាតឱ្យមានការកែច្នៃជាលក្ខណៈប្រពៃណីនូវគ្រឿងចម្លាក់ សម្ភារៈប្រើប្រាស់វត្ថុអនុស្សាវរីយ៍ ដែលធ្វើពីឈើត្នោតប្រកបដោយការសន្សំសំចៃខ្ពស់ និងផលិតផលត្នោតកែច្នៃផ្សេងទៀត សម្រាប់បម្រើទីផ្សារក្នុងស្រុក ឬក្រៅស្រុក ដើម្បីបង្កើនមុខរបរជូនប្រជាពលរដ្ឋដោយមានការអនុញ្ញាត ពីសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

៩-ហាមឃាត់ដាច់ខាតចំពោះអាជីវករទាំងឡាយណាដែលបំផុស និង ជំរុញចលនាកាប់ដើមត្នោតជាលក្ខណៈប្រមូលផ្តុំ ដើម្បីធ្វើការប្រមូលទិញ ការដឹកជញ្ជូន ការធ្វើសន្និធិក្នុងគោលបំណងពាណិជ្ជកម្ម ឬ ការបង្កើតរោងចក្រ រោងសិប្បកម្មកែច្នៃដើមត្នោត ឈើត្នោតជាលក្ខណៈឧស្សាហកម្ម ឬ ក្នុងគោលបំណងនាំចេញដើមត្នោត ឬ ឈើត្នោត។

១០-អាជ្ញាធរមានសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែន ត្រូវហាមឃាត់ដាច់ខាតការនាំចេញដើមត្នោតឈើត្នោតទៅក្រៅប្រទេស ។

១១-ការនាំចេញសំណាកដើមត្នោត ឈើត្នោតកែច្នៃ ផលិតផលត្នោតក្នុងគោលបំណងសិក្សាស្រាវជ្រាវ តាំងពិព័រណ៍ ឬ ដើម្បីប្រយោជន៍សាធារណៈផ្សេងទៀត ត្រូវសម្រេចដោយរាជរដ្ឋាភិបាល។

១២-អាជីវករទាំងឡាយណាដែលប្រព្រឹត្តល្មើសចំពោះការហាមឃាត់ក្នុងបទបញ្ជានេះ នឹងត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ទទួលបានបទបញ្ជានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងមហាផ្ទៃ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និង ចាត់ចែងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-សាលាខេត្ត ក្រុង
-ឯកសារ-កាលប្បវត្តិ